**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.......៥៥២...........ក. ស. ភ.

ថ្ងៃអង្គារ ១៣រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ប្រេងរំអិល និងខ្លាញ់គោ

## ប្រចាំឆ្នាំ២០២៦

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈស្តីពីការផ្គត់ផ្គង់ប្រេងរំអិល និងខ្លាញ់គោ ប្រចាំឆ្នាំ២០២៦។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១២..ខែសីហា..ឆ្នាំ២០២៦ តទៅរៀងរាល់**ម៉ោងធ្វើការ** (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤ ៦៩៥/ ០១០ ៤៤៤ ៦៣៤)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ **នៅម៉ោង**.១៤:៣០.........ថ្ងៃទី.១១....ខែ.កញ្ញា...ឆ្នាំ២០២៦។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ...១៤:៣០.........ថ្ងៃទី.១១...ខែ.កញ្ញា....ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

PHNOM PENH AUTONOMOUS PORT

**ជួន សុខេម**

**ចម្លងជូន**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ